ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អគ្គនាយកដ្ឋានយោធសេវា
នាយកដ្ឋានព័ត៌មាន
លេខ: ០៣៣/ន៣
២០១៦

# សេចក្តីប្រកាសព័ត៌មាន

នាយកដ្ឋានព័ត៌មាន អគ្គនាយកដ្ឋាន យោធសេវា ក្រសួងការពារជាតិ សូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា តបតាមការអញ្ជើញរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ គណប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ ដឹកនាំដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជានិងអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ពីថ្ងៃទី២៤ ដល់ថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៦ ។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចរយៈពេល៤ថ្ងៃ ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៦ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់** អមដំណើរដោយប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ នឹងអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានលើកទី១០ (The 10th Asean Defence Ministers Meeting ADMM) និងកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនទៀតក្នុងទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ។/.

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦

នាយកដ្ឋានព័ត៌មាន